# ការសម្លុតធ្វើបាប និង ការយាយី

## អ្វីៗដែល មាតាបិតា និង អាណាព្យាបាល ត្រូវដឹង

- **សូមឲ្យនិយមន័យនូវអ្វីដែលយើងលើកមកនិយាយ។**

**តើអ្វីទៅគឺជា ការសម្លុតធ្វើបាប**? មិនមែនគ្រប់ជម្លោះទាំងអស់ គឺជាការសម្លុតធ្វើបាបនោះទេ។ ការសម្លុតធ្វើបាប គឺជាអាកប្បកិរិយាដែល ធ្ងន់ធ្ងរ រាលដាល មិនឈប់ឈរ ដែលបង្កឲ្យមានការរំខានដល់ការអប់រំរបស់សិស្ស ឬ បរិយាកាសរបស់សាលា។ ការសម្លុតធ្វើបាប គឺជាអំពើរបស់មនុស្សដែលប្រើអំណាចធ្វើបាបដល់អ្នកដទៃ ម្តងហើយម្តងទៀត។

**តើអ្វីទៅគឺជា ការយាយី** ? ការយាយី គឺជា ពាក្យសំដី ការសរសេរ រូបគំនូរ ឬ កាយវិការ ដែលមិនស្វាគមន៍ ដោយមូលហេតុទាក់ទងទៅនឹង ភេទ អាយុ សាសន៍ ពណ៌សម្បុរ ទំនោរនៃសេចក្តីស្រឡាញ់ ការបង្ហាញពីអត្តសញ្ញាណអំពីភេទ ជាតិកំណើត សាសនា ពិការភាព កម្រិតនៃការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស ស្ថានភាពជីវភាព និង/ឬ ជំនឿនៃនយោបាយ ណាមួយរបស់បុគ្គល។

- **តើ មាតាបិតា និង អាណាព្យាបាល ត្រូវធ្វើដូចម្តេច**?

**សូមប្រាប់កូនថា** ការសម្លុតធ្វើបាប និង ការយាយី ត្រូវបានគេហាមឃាត់។ វាគឺជាអំពើខុសឆ្គង ពួកគេមិនត្រូវប្រព្រឹត្តវាទេ ហើយបើពួកគេរងនូវអំពើនេះ ពួកគេត្រូវប្រាប់លោកអ្នក និង គ្រូរបស់ពួកគេ។

**ឧទាហរណ៍** គឺជាវិធីដ៏ល្អបំផុតដើម្បីបង្ហាញក្មេងនូវអ្វីៗដែលលោកអ្នកចង់ប្រាប់។ ឧទាហរណ៍ ការធ្វើត្រាប់តាម ឬ ការគម្រាមកំហែងចង់ធ្វើបាបដល់អ្នកណាម្នាក់ ដោយសារ ពូជសាសន៍ ភាសាកំណើត ឬ ទំនោរនៃសេចក្តីស្រឡាញ់ របស់ពួកគេ គឺមិនមែនជាអំពើត្រឹមត្រូវទេ - នេះជាការយាយី។ ការគម្រាមកំហែងអ្នកណាម្នាក់តាមអ៊ិនធ័រណិតគឺជា ការសម្លុតធ្វើបាបតាមគ្រឿងអេឡិចត្រូនិច!

- **បើសិនជាលោកអ្នកសង្ស័យថាកូនរបស់លោកអ្នកកំពុងទទួលរង ការសម្លុតធ្វើបាប ឬ ការយាយី** លោកអ្នកត្រូវ៖

**រាយការណ៍** អំពីស្ថានភាពនេះទៅគ្រូរបស់កូន និង/ឬ រដ្ឋបាលសាលា។ សួរកូនរបស់លោកអ្នក៖ មានអ្នកណាខ្លះដែលជាប់ទាក់ទិន តើពួកគេបានធ្វើអ្វីខ្លះ តើអំពើទាំងនោះកើតឡើងនៅ ពេលណា និង កន្លែងណា។ បំពេញ លិខិត រាយការណ៍ និង ស៊ើបអង្កេតអំពី ការសម្លុតធ្វើបាប និង ការយាយី របស់ក្រសួងអប់រំ (លិខិតនេះមាននៅតាមសាលា និងនៅក្នុងវ៉ិបសៃរបស់ក្រសួងអប់រំ៖ http://webgui.phila.k12.pa.us/offices/l/language-khmer/-allegation-of-bullying បើសិនជាគ្មានចម្លើយពីសាលា សូមទូរស័ព្ទទៅខ្សែទូរស័ព្ទសំខាន់សម្រាប់ការសម្លុតធ្វើបាប របស់ក្រសួងអប់រំ លេខ ២១៥-៤០០-SAFE។

**ផ្តល់**មធ្យោបាយល្អៗដល់កូនរបស់លោកអ្នក ដូចជាសុំឲ្យគ្រូជួយ ស្នើសុំជួបប្រជុំជាមួយអ្នកផ្តល់ឱវាទនៅសាលា និង គេចពីអ្នកសម្លុតធ្វើបាបគេ។

អ្វីដែល**មិនអាច**ដោះស្រាយបាន? ការជំរុញឲ្យកូនវាយតប់គេវិញ។ ការជំរុញឲ្យកូនធ្វើមិនដឹងមិនឮ។ ទៅរកក្មេងដែលជាអ្នកសម្លុតធ្វើបាបគេ។

- **អ្វីដែលលោកអ្នកចង់បាន**?

សាលាត្រូវតែធ្វើការស៊ើបអង្កេត ដើម្បីឲ្យដឹងថាតើទំនាស់នេះជា ការសម្លុតធ្វើបាប ការយាយី ឬ អំពើផ្សេងទៀត ដែលត្រូវការដោះស្រាយ។ គេត្រូវផ្តល់ដំណឹងដល់លោកអ្នកអំពីលទ្ធផលនៃការស៊ើបអង្កេត និង វិធានការបន្ទាប់ទៀត ថាតើសាលាត្រូវធ្វើដូចម្តេច។ ទោះជាយ៉ាងនេះក្តី ច្បាប់រក្សាការសម្ងាត់របស់រដ្ឋសហព័ន្ធ ហាមមិនឲ្យចែកចាយព័ត៌មានដែលទាក់ទងនឹងការដាក់វិន័យ ឬការធ្វើអន្តរាគមន៍ របស់សិស្សដទៃទៀតទេ។

- **បើមានសំណួរ**?

សូមនិយាយជាមួយ គ្រូ ឬ នាយកសាលា របស់កូនលោកអ្នក។ ចូលរួមអង្គប្រជុំរបស់មាតាបិតា ដែលរៀបចំឡើងពីដើមដល់ចុងឆ្នាំ ដើម្បីពិភាក្សាពីបញ្ហាទាំងនេះ។ ទូរស័ព្ទ ឬ អ៊ីមែល ទៅភ្នាក់ងារផ្នែកធ្វើតាមតម្រូវការ សម្រាប់ ការសម្លុតធ្វើបាប និង ការយាយី របស់ក្រសួង៖ Diane Bernoff Sher, Esquire លេខ ២១៥-៤០០-៥៦១០ អ៊ីមែល dbsher@philasd.org។